01624231



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2019, 16:43
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Brenda HOLLIS (បម្រុង)

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

**<u>ជនជាប់ចោទ</u>**

នួន ជា

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

សុន អរុណ
លីវ សុវណ្ណា
Doreen CHEN

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”) បានទទួល លិខិតបញ្ជាក់មរណភាពរបស់ជនជាប់ចោទ នួន ជា[1]។

## I. សាវតារ

1. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយចោទប្រកាន់ នួន ជា ខៀវ សំផន អៀង សារី អៀង ធីរិទ្ធ និង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) ថាបាន ប្រព្រឹត្តបទឧក្រិដ្ឋកម្មផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[2]។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ នួន ជា ត្រូវបានឃុំខ្លួនតាមអំណាចដីការបស់សហចៅក្រមស៊ើបអង្កេត បានបញ្ជូនមកមន្ទីរឃុំ ឃាំងរបស់ អ.វ.ត.ក ហើយបានជូនដំណឹងពីបទចោទប្រឆាំងនឹងជនជាប់ចោទរូបនេះ[3]។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចោទប្រកាន់ប្រឆាំងនឹង នួន ជា ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជ សាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ និងការរំលោភបំពានលើ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[4]។ អង្គបុរេជំនុំជម្រះបានសម្រេចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១[5]។

2. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការ នីតិវិធីប្រឆាំងនឹងជនជាប់ចោទទៅជាការជំនុំជម្រះលើកទីមួយ ដែលហៅថាសំណុំរឿង ០០២/០១[6]។ អង្គ

---

[1] លិខិតមរណភាពរបស់ នួន ជា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/1.1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3។ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានបំណែកជាសំណុំរឿងលេខ ០០១/១៨-កក្កដា-២០០៧។ *សូមមើល* ដីកាបំបែកសំណុំរឿង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ D18។

[3] ដីកាបង្គាប់ឲ្យឃុំខ្លួន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C9។

[4] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[5] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/2/12។

[6] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារ E124/7។

ជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤ ថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយបានផ្តន្ទាទោសជនជាប់ចោទទាំងពីររូបដាក់ពន្ធនាគារអស់មួយជីវិត[7]។ នៅពេលប្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលការផ្តន្ទាទោសមួយចំនួន តម្កល់ការផ្តន្ទាទោសផ្សេងទៀត និងបានសម្រេចរក្សាទុកទោសដាក់ពន្ធនាគារអស់មួយជីវិតដដែល[8]។ ក្រោយពេលបញ្ចប់សវនាការលើកទីពីរ ដែលហៅថា សំណុំរឿង ០០២/០២[9] នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថាជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩[10]។

3. ជនជាប់ចោទ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩[11]។ ជនជាប់ចោទបានទទួលមរណភាពនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងរាជធានីភ្នំពេញ[12]។

---

[7] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ *សូមមើល* សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E270/1។ អៀង ធីរិទ្ធ ត្រូវបានសន្និដ្ឋានថាពុំមានសម្បទានដើម្បីចូលរួមការជំនុំជម្រះនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ *សូមមើល* សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359/1។

[8] បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។

[9] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1។

[10] ប្រតិចារិកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ឯកសារ E1/529.1។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ឯកសារE465។

[11] សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៩ ឯកសារ E465/3/1។

[12] លិខិតមរណភាពរបស់ នួន ជា ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/1.1។

4. នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់"សំណើបន្ទាន់ពាក់ព័ន្ធនឹងផលប៉ះពាល់លើកិច្ចដំណើរនីតិវិធីបណ្តឹងសាទុក្ខនៃមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា"[13]។

## II. ការពិភាក្សា

5. អនុលោមតាមមាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មរណភាពរបស់ជនល្មើស ត្រូវរលត់បណ្តឹងអាជ្ញាប្រឆាំងនឹងជននោះ។ អនុលោមតាមវិធាន ២៣*ស្ទួន*(៦) នៃវិធានផ្ទៃក្នុង ដំណើរការនីតិវិធីបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទនៅ អ.វ.ត.ក. ត្រូវបញ្ចប់នៅពេលមរណភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តាមច្បាប់កម្ពុជា និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. មរណភាពរបស់ នួន ជា មានអានុភាពរលត់បណ្តឹងអាជ្ញា និងបញ្ចប់បណ្តឹងរដ្ឋប្បវេណីចំពោះរូបគាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ។

6. ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុងពុំបានបញ្ជាក់ច្បាស់លាស់អំពីផលវិបាកនៃការដាក់ពិរុទ្ធភាពពីតុលាការជាន់ដំបូងប្រឆាំងនឹងជនជាប់ចោទ ដែលបានស្លាប់បន្ទាប់ពីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ សេចក្តីសម្រេចមុនៗរបស់ អ.វ.ត.ក. ដែលបញ្ចប់ដំណើរការនីតិវិធី ពុំមានលក្ខណៈស្រដៀងគ្នានឹងរឿងក្តីបច្ចុប្បន្នឡើយ៖ អៀង សារី ស្លាប់នៅមុនការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១[14] ចំណែក អៀង ធីរិទ្ធ ស្លាប់ក្នុងខណៈពេលដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបន្ទាប់ពីរកឃើញថាពុំមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ[15]។ ទោះជាយ៉ាងណាក្តី ក្នុងករណីទាំងពីរនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា រាល់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទរូបនេះត្រូវបានរលត់ដោយសារមរណភាពរបស់ពួកគាត់។ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី(ICTY) បានបង្ហាញថា ទោះបីជាអង្គជំនុំជម្រះឧទ្ធរណ៍បានចេញសេចក្តីសម្រេចបន្ទាប់ពីមរណភាពរបស់ជនម្ចាស់បណ្តឹងក៏ដោយ ក៏គ្មានការចេញសាលដីកាណាមួយពាក់ព័ន្ធទៅនឹងជនជាប់ចោទ ដែលបានដាក់បណ្តឹងសាទុក្ខនៅមុនពេលមរណភាព រួមជាមួយនឹងសារណាដែលមានទឡ្ហីករណ៍

[13] សំណើបន្ទាប់ពាក់ព័ន្ធនឹងផលប៉ះពាល់លើដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៃមរណភាពរបស់ នួន ជា មុនពេលចេញសាលដីកា ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F46/2។

[14] ការបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹង អៀង សារី ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ E270/1។

[15] ការបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ E359/1។

បណ្តឹងសាទុក្ខ និងមានសម្អាងហេតុពេញលេញមកកាន់អង្គជំនុំជម្រះឡើយ[16]។ គោលជំហរនេះ បញ្ជាក់កាន់តែច្បាស់ថែមទៀតនៅក្នុងស្ថានភាពដូចករណីបច្ចុប្បន្ន ដែលអង្គជំនុំជម្រះលើបណ្តឹងសាទុក្ខ ពុំទាន់បានពិនិត្យពេញលេញលើបណ្តឹងសាទុក្ខ និងស្ថិតក្នុងស្ថានភាពរៀបចំចាប់ផ្តើមពិភាក្សាសម្រេចលើខ្លឹមសារនៃកំហុសអង្គច្បាប់ ឬអង្គហេតុដែលរងចោទប្រកាន់នោះ ក្នុងទម្រង់សង្ខេប ដូចបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[17]។

7. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹង នួន ជា ប៉ុន្តែ បន្តទទួលពិនិត្យលើសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធទៅនឹង *ក្នុងចំណោមនោះ*ផលប៉ះពាល់នៃមរណភាពទៅលើសាលក្រម និងការដាក់ពិរុទ្ធភាពជាមូលដ្ឋាន។

[16] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Delić* សេចក្តីសម្រេចស្តីពីផលវិបាកនៃកិច្ចដំណើរការនីតិវិធី តុលាការ ICTY សំណុំរឿងលេខ IT-04-83-A ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Popović និងជនដទៃទៀត* សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹង Milan Gvero តុលាការ ICTY សំណុំរឿងលេខ IT-05-88-A ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣។

[17] *សូមមើល* វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ឯកសារលេខ F3/3 កថាខណ្ឌ ៨ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៧ (ទទួលស្គាល់ថា "ការបញ្ជាក់អំពីសេចក្តីដកស្រង់ខ្លះសម្រាប់កំហុសនានា [...] ពុំមានលក្ខណៈទូលំទូលាយ")។

## III. ផ្នែកសម្រេចសេចក្តី

8. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**ប្រកាស**ថា មរណភាពរបស់ជនជាប់ចោទ នួន ជា មានអានុភាពរលត់បណ្តឹងអាជ្ញាលើរូបគាត់ និងបញ្ចប់រាល់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងរូបគាត់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និង

**បន្តទទួលពិនិត្យ**លើសំណើសុំបន្ទាន់របស់ក្រុមមេធាវីការពារក្តី នួន ជា។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**